# ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួត ពិនិត្យទំនិញគ្រោះថ្នាក់ បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យលើសេចក្តី ព្រាងច្បាប់ស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់ នៅទីស្តីការក្រសួង ។

ព្រឹកថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៧ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួត ពិនិត្យទំនិញគ្រោះថ្នាក់ បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យលើសេចក្តី ព្រាងច្បាប់ស្តីពីការគ្រប់គ្រងទំនិញគ្រោះថ្នាក់នៅទីស្តីការក្រសួង។



មានប្រសាសនិបើកអង្គប្រជុំ ឯកឧត្តមទេស រដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថា៖ ការគ្រប់គ្រងទំនិញគ្រោះថ្នាក់របស់កម្ពុជាយើងនាពេលបច្ចុប្បន្ននៅមានកំរិត មិន

ទាន់ផានាបាននូវកិច្ចការពារសុវត្ថិភាពអោយបានខ្ពស់នៅឡើយ ។ ជាក់ស្តែងនៅតាមប្រទេសក្នុងតំបន់មួយចំនួនរួមទាំងកម្ពុជាផង ធ្លាប់បានប្រឈម និងរងគ្រោះទាក់ទងនិងទំនិញគ្រោះថ្នាក់នេះផងដែរ ដូចជាៈ-ករណីផ្ទុះឆេះឃ្លាំងស្តុកសារធាតុគីមី នៅទីក្រុងធានជីន នៃប្រទេសចិន-ករណីផ្ទុះឆេះយ៉ាងសន្ធោសន្ធៅនៅរោងចក្រគ្រប់គ្រងកាកសំណល់គីមីនៅក្នុងប្រទេសសឹង្ហបុរី-គ្រោះថ្នាក់ក្រឡាប់រថយន្តដឹកប្រេងឥន្ធនៈនៅតាមបណ្តោយផ្លូវជាតិលេខ៤ក្នុងខេត្តកំពង់ស្ពឺ-គ្រោះថ្នាក់រថយន្តដឹកផាវផ្ទុះឆេះស្លាប់មនុស្សពីរនាក់នៅខេត្តបន្ទាយមានជ័យ-រួមទាំងគ្រោះមហន្តរាយនៅទីតាំងដទៃទៀតលើពិភពលោក ដែលពាក់ព័ន្ធដល់ការផលិត ការដឹកជញ្ជូន ការ នាំចូល ការនាំចេញ ការស្តុកទុក ការប្រើប្រាស់ទំនិញគ្រោះថ្នាក់និងសារធាតុគ្រោះថ្នាក់ជាដើម។



ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសង្កត់ធ្ងន់ថា៖ការធ្វើសេចក្តីព្រាងច្បាប់នេះ មិនមានបំណង ទាញយកដែនសមត្ថកិច្ចក្រសួង-ស្ថាប័នដ៏ទៃមកគ្រប់គ្រងទេ ។ ប៉ុន្តែ សេចក្តីព្រាងច្បាប់នេះ បាន ដើតួជាអ្នកសម្របសម្រួល មានក្បាលម៉ាស៊ីន គ្រប់គ្រងច្បាស់លាស់ ធ្វើយ៉ាងណាកុំអោយ មានឧបាតុហេតុកើតឡើងហើយ គ្មានស្ថាប័នណាមួយចេញមុខទទួលខុសត្រូវ រឺុញការ ទទួលខុសត្រូវដាក់គ្នា ។



ម៉្យាងច្បាប់នេះ ក្រៅពីដើតួរជាអ្នកសម្របសម្រួលហើយ នៅមាន យន្តការបន្ថែម ដ៏ទៃទៀតដូចជា៖ការប្រមូលទិន្នន័យ -ការផ្តល់ព័ត៌មានអោយគ្នាទៅវិញ ទៅមក និងយន្តការសហការគ្រប់គ្រង ទប់ស្កាត់ និងប្រើប្រាស់នីតិវិធី បច្ចេកទេសនានា ដើម្បីដោះស្រាយពេលមានគ្រោះមហន្តរាយកើត ឡើង ។ នេះជាការគិតគូខ្ពស់បំផុតរបស់ប្រមុខរាជរដ្ឋាភិបាល សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលសម្តេច បានចុះហត្ថលេខា រួចហើយ លើសេចក្តីសម្រេចបង្កើតគណៈ កម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យគ្រោះថ្នាក់ កាលពីថ្ងៃទី

២២ ខែ មិថុនា ឆ្នាំ២០១៦ កន្លងទៅ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បាន បញ្ជាក់ជំហរចុងក្រោយថា៖ដើម្បីអោយច្បាប់នេះ ដែល មាន ០៨ជំពូក និង៩២ មាត្រា អនុវត្តទៅមានភាព រលូន និងប្រសិទ្ធិភាពខ្ពស់នោះ ការពិនិត្យកែសម្រួល លើសេចក្តីព្រាងច្បាប់នាថ្ងៃនេះ លុះត្រាតែតំណាងអន្តរក្រសួងទាំងអស់មានការ ឯកភាពជាធ្លុងមួយ ។



ដូច្នេះ ឯកឧត្តម ទេស រដ្ឋមន្ត្រី បានស្នើដល់សមាជិកអង្គប្រជុំទាំងអស់ យកសេច ក្តីព្រាងច្បាប់នេះពិនិត្យឡើងវិញ និងបញ្ជាក់ជំហរចុងក្រោយពីប្រធានស្ថាប័ ននីមួយៗ តើគួរកែសម្រួលចំណុចកន្លែងណា?និងតើគាំទ្រអោយបង្កើតច្បាប់នេះ ដែររឺទេ? ក្នុងរយៈពេលពីរសប្តាហ៍ក្រោយ ដើម្បីយើងអាចធ្វើសំយោគ មតិជាចុង ក្រោយ។



សូមបញ្ជាក់ថាៈក្នុងមាត្រា២ នៃច្បាប់នេះ បាន បញ្ជាក់ថា៖ច្បាប់នេះមានគោលដៅកំណត់អំពី យន្តការ និងវិធានការសម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ដែលអាចបង្ក មហន្តរាយដល់ មនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ បរិស្ថាន សន្តិសុខសង្គម និង រឺ សកម្មភាពពាក់ព័ន្ធទាំងឡាយ ដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយឡែកក្នុងមាត្រា៨៨ បានកំណត់ថា៖ក្នុងករណីដែលច្បាប់ផ្សេងទៀត មានបទប្បញ្ញត្តិនិងការគ្រប់គ្រងទំនិញគ្រោះថ្នាក់រួចហើយ បទប្បញ្ញត្តិទាំងនោះត្រូវនៅជាធរមាន លើក លែងតែបទប្បញ្ញត្តិទាំងឡាយណាដែលមិន មានចែងនៅក្នុងច្បាប់នោះ ត្រូវយកមកអនុវត្តបំពេញបន្ថែម ។